គណបក្ស សិទ្ធិមនុស្ស
HUMAN RIGHTS PARTY
បំរើ ការពារ កសាង

លេខ ០០៥០/១០ គ.ស.ម

# សេចក្តីថ្លែងការណ៍

ក្រោយពីបានពិនិត្យសិក្សាយ៉ាងល្អិតល្អន់ លើខ្លឹមសារនៃសេចក្តីព្រាងច្បាប់រួចមក **គណបក្សសិទ្ធិមនុស្ស** សំដែងនូវការព្រួយបារម្ភយ៉ាងខ្លាំងចំពោះច្បាប់ស្តីពី " **ការផ្តល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិដល់ជនបរទេស** " ដែលបានផ្តល់សិទ្ធិអោយជនបរទេសមានសិទ្ធិទិញលំនៅដ្ឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជាចាប់ពីជាន់ទី១ឡើងទៅ។ ទោះបីជាគណបក្សសិទ្ធិមនុស្សចង់អោយមានច្បាប់នេះក៏ដោយ ក៏គណបក្សសិទ្ធិមនុស្សពុំអាចគាំទ្រច្បាប់នេះបានដែរព្រោះ :

១- ច្បាប់បែបនេះគួរត្រូវអនុម័តក្នុងកាលៈទេសៈសមស្របណាមួយដែលកម្ពុជាបានអនុវត្តយ៉ាងល្អ និងមានប្រសិទ្ធិភាពនូវច្បាប់សញ្ជាតិ និងច្បាប់អន្តោប្រវេសន៏ដែលរដ្ឋសភាបានអនុម័តតាំងពីឆ្នាំ ១៩៩៦ កន្លងមកម្ល៉េះ ។

២- **អ្នកតំណាងរាស្ត្រ គណបក្សសិទ្ធិមនុស្ស** បានសរសេរលិខិតតាមរយៈប្រធានរដ្ឋសភាជូនក្រសួងមហាផ្ទៃដើម្បីស្នើសុំឱ្យ **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** បំភ្លឺនូវចំនួនជនបរទេសដែលបានចូលសញ្ជាតិខ្មែរក្នុងរយៈពេលកន្លងមក។

សំណួរខាងលើរហូតមកទល់នឹងពេលនេះ អ្នកតំណាងរាស្ត្រ **គណបក្សសិទ្ធិមនុស្ស**នៅពុំទាន់បានទទួលចម្លើយពី**ក្រសួងមហាផ្ទៃ**នៅឡើយទេ ។

ការដែលក្រសួងមហាផ្ទៃ មិនអាចគ្រប់គ្រងបញ្ហាខាងលើនេះបានល្អ និងការអនុវត្តន៏ច្បាប់សញ្ជាតិ និងច្បាប់អន្តោប្រវេសន៏មិនទាន់បានត្រឹមត្រូវ ហើយស្រាប់តែមានច្បាប់ដែលផ្តល់សិទ្ធិឱ្យជនបរទេស មានសិទ្ធិទិញលំនៅដ្ឋានជាន់ទី១បានបែបនេះនឹងបណ្តាលអោយមានគ្រោះថ្នាក់ដល់ប្រជាពលរដ្ឋខ្មែរ និងប្រទេសកម្ពុជាពុំខានក្នុងពេលអនាគត ។

រាជធានីភ្នំពេញ.ថ្ងៃទី០១ ខែមេសា ឆ្នាំ២០១០

គណបក្សសិទ្ធិមនុស្ស

ពតិមានបន្ថែមសូមទាក់ទង :

ទូរស័ព្ទលេខ : ០១៧ ៥៧០ ១២៧ / ០១៦ ៤៣៥ ១០៦

Address: #72-74 Street 598, Sangkat Boeng Kok 2, Khan Tuol Kok, Phnom Penh, Cambodia.
Tel: (+855) 17 303 900 / 023 884 649 | Email: hrpcambodia@yahoo.com , Website. www.hrpcambodia.info